UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**

**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

## សេចក្តីថ្លែងការណ៍របស់ការិយាល័យ OHCHR អំពីករណីរបស់ទូច សារ៉ន

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩

កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ លោកទូច សារ៉នត្រូវបានតុលាការខេត្តកំពង់ធំផ្តន្ទាទោសពីបទបង្ខាំងអ្នកស្រីទឹម ណានខុសច្បាប់។ គាត់ត្រូវបានតុលាការដាក់ទោសឲ្យជាប់ពន្ធនាគារចំនួនបីឆ្នាំ និងត្រូវបានពិន័យជាប្រាក់ចំនួន២៥០០ ដុល្លារអាមេរិក។ ជនជាប់ចោទបីនាក់ផ្សេងទៀត គឺឈ្មោះម៉ែន វណ្ណៈ ហ្សូរ សារ៉ាត់ និងថន រិទ្ធី ត្រូវបានតុលាការកាត់ទោស *កំបាំងមុខ* ក្នុងករណីដូចគ្នាដែលត្រូវទទួលទោសគុកពីបីទៅប្រាំឆ្នាំ។

លោកទូច សារ៉ន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨ ហើយបានជាប់ពន្ធនាគារតាំងពីពេលនោះមក។ នៅពេលចាប់ខ្លួន គាត់ជាមេឃុំពង្រ ស្រុកបារាយណ៍ ដែលមាននិន្នាការជាមួយ គណបក្សសមរង្ស៊ី(SRP)។ ការចាប់ខ្លួនបានកើតមាននៅមុនពេលបោះឆ្នោតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៨ គឺជាពេលមួយដែលសមាជិកគណបក្សប្រឆាំងជាច្រើននាក់ ជារឿយៗ ត្រូវបានគេបំភិតបំ ភ័យ និងអូសទាញឲ្យប្តូរសម្ព័ន្ធភាពរបស់ខ្លួនទៅគណបក្សប្រជាជន(CPP)។ អ្នកស្រីទឹម ណាន ដែល ជាមេដឹកនាំស្ត្រីមួយរូប ដែលសកម្មនៅក្នុងឃុំគាត់ ដែលមាននិន្នាការជាមួយគណបក្ស សម រង្ស៊ី (SRP) បានចុះចូលជាមួយគណបក្សប្រជាជន (CPP) ក្នុងបរិបទនេះ។ ការចោទប្រកាន់របស់គាត់ពី ការបង្ខាំងខ្លួនខុសច្បាប់ដោយបុរសទាំងបួននាក់នោះ គួរតែកើតមានឡើងនៅថ្ងៃទី១៦ និងទី១៧ ខែកុម្ភៈ ឆ្នាំ២០០៨ នៅពេលដែលលោកស្រីកំពុងពិចារណាអំពីការប្តូរសម្ព័ន្ធភាពនយោបាយម្លេះ។

ការិយាល័យ OHCHR បានពិនិត្យករណីនេះយ៉ាងដិតដល់បំផុត រួមទាំងតាមរយៈការពិភាក្សា និងការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធទាំងអស់ ទាំងនៅរាជធានីភ្នំពេញ ទាំងនៅខេត្តកំពង់ធំ ក្នុងគោលបំណងស្វែងយល់ឲ្យបានស៊ីជម្រៅ និងជាក់ច្បាស់ថែមទៀតអំពីដំណើររឿងនេះ។ ការិយាល័យ(OHCHR) បានរកមិនឃើញមានភស្តុតាងណាមួយគួរឲ្យជឿបាន ដើម្បីគាំទ្រការចោទប្រកាន់ថា អ្នកស្រីទឹម ណាន ត្រូវបានលោកទូច សារ៉នឬអ្នកផ្សេងទៀតបង្ខាំងឬចាប់ពង្រត់ដោយខុសច្បាប់នោះទេ។

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342  Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org   Website: http://cambodia.ohchr.org

ដើម្បីជាវិភាគទានដល់ការស៊ើបអង្កេត ការិយាល័យ(OHCHR) បានចែករំលែកព័ត៌មានដែលខ្លួនប្រមូលបាន ជាមួយតុលាការខេត្តកំពង់ធំ និងជាមួយតុលាការកំពូលកាលពីខែវិច្ឆិកា ឆ្នាំ២០០៨ នៅពេលដែលតុលាការកំពូល កំពុងពិនិត្យអំពីការស្នើសុំនៅក្រៅឃុំ របស់លោកទូត សារ៉ន។ ការិយាល័យ OHCHR ក៏បានលើកយកកង្វល់របស់ខ្លួនប្រាប់មន្ត្រីជាន់ខ្ពស់ និងមន្ត្រីថ្នាក់ខេត្តនៃគណបក្សប្រជាជន(CPP) ជ្រាបផងដែរ។

ការសន្និដ្ឋានថាគ្មានភស្តុតាងណាមួយគួរឲ្យជឿបានដើម្បីគាំទ្រការចោទប្រកាន់ពីការបង្ខាំងមនុស្សខុសច្បាប់នេះ ត្រូវបានការិយាល័យ OHCHR បញ្ជាក់យ៉ាងច្បាស់ តាមរយៈការសង្កេតមើលសវនាការជុំនំជម្រះក្តីនៅតុលាការខេត្តកំពង់ធំ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។ ការចោទប្រកាន់មិនបានបង្ហាញភស្តុតាងស៊ីសង្វាក់ដែលគួរឲ្យជឿបានថាអំពើល្មើសមួយពិតជាបានប្រព្រឹត្ត ប្រាកដមែននោះទេ។ ការកាត់សេចក្តីនេះ ផ្អែកសំខាន់តែលើចំលើយដែលមិនស៊ីសង្វាក់របស់អ្នកស្រីទឹម ណានតែប៉ុណ្ណោះ។ ចំលើយរបស់សាក្សីបីនាក់ ដែលនគរបាលទទួលបាន គឺសុទ្ធសឹងជាការគាំទ្រដោយប្រយោលប៉ុណ្ណោះហើយ មិនបានផ្តល់ឱកាសឲ្យមេធាវីចុងចោទសួរដេញដោល អំពីចំលើយជាលាយលក្ខណ៍អក្សរទាំងនោះនៅក្នុងតុលាការឡើយ។ ភស្តុតាងដោះបន្ទុកសំខាន់ៗឯទៀត រួមទាំងចំលើយរបស់សាក្សីផងនោះ តុលាការហាក់ដូចជាមិនអើពើយកចិត្តទុកដាក់។ ថ្វីបើគ្មានភស្តុតាងគ្រប់គ្រាន់ក្តី ក៏តុលាការបានសំរេចកាត់ទោសបុរសទាំងនោះដែរ។

ការិយាល័យ OHCHR ជឿថាការកាត់ទោសលោកទូត សារ៉ន និងបុរសបីនាក់ផ្សេងទៀតនោះគឺជាការអនុវត្តយុត្តិធម៌មិនបានត្រឹមត្រូវរបស់តុលាការ ហើយថាតុលាការ ទំនងជាមិនបានសំរេចរឿងក្តីនេះទៅតាមអង្គហេតុឡើយ ប៉ុន្តែគឺស្ថិតក្រោមឥទ្ធិពលនយោបាយទៅវិញទេ។ ករណីនេះបង្ហាញឲ្យឃើញពីសារៈសំខាន់សំរាប់ភាពអាចជឿបាននៃប្រព័ន្ធយុត្តិធម៌ អំពីសេចក្តីត្រូវការឲ្យគ្រប់ភាគីទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវឯករាជ្យភាពរបស់តុលាការ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា។

លោកទូត សារ៉ន បាននឹងកំពុងជាប់ពន្ធនាគាររយៈពេលមួយឆ្នាំមកហើយចំពោះបទល្មើសមួយដែលគាត់មិនបានប្រព្រឹត្ត។ គាត់អាចសំរេចចិត្តប្តឹងឧទ្ធរណ៍។ ប្រសិនជាគាត់ប្តឹងមែននោះ វាជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ជាអ្នកពិនិត្យករណីនេះឡើងវិញផ្អែកលើភស្តុតាងទាំងអស់ដែលមាន និងស្របទាំងស្រុងតាមបទដ្ឋានសវនាការប្រកបដោយភាពយុត្តិធម៌ ដើម្បីធានាថា ការអនុវត្តយុត្តិធម៌មិនបានត្រឹមត្រូវរបស់តុលាការ នឹងមិនអាចកើតមានឡើយ។

End.